## កម្មវិធីរៀនសំរាប់ម្នាក់ៗ

✪ រយៈពេលសិក្សាភាសាបានចាត់ចែងឡើងតំរូវទៅតាមសេចក្តីត្រូវការនឹងគោលបំណងរបស់អ្នករៀន ។

✪ គ្រូបង្រៀនដល់ផ្ទះមានកម្មវិធីបង្រៀនខាងរបៀបនិយាយឱ្យបានត្រឹមត្រូវនឹងតាមវេយ្យាករណ៍ ។

✪ គ្រូបង្រៀនដល់ផ្ទះបានបញ្ចូលមេរៀនខាងច្បាប់ចរាចរសំរាប់រៀនបើកឡានដើម្បីប្រឡងយកប័ណ្ណបើកបររថយន្តនឹងរៀនខាងរបៀបសុំម៉ោងពេលទៅជួបពេទ្យឬជួបអ្នកផ្សេងទៀតជាដើម ។

✪ ក្រុមគ្រូបង្រៀនភាសាអង់គ្លេស ESOL ដល់ផ្ទះគ្រប់តំបន់មានប្រដាប់ប្រដាបង្រៀនច្រើនយ៉ាងណាស់សំរាប់ផ្តល់ឱ្យគ្រូ យកទៅបង្រៀនសិស្សដូចជា ម៉ាស៊ីនថតសម្លេងចាក់កាសែត ថេប, សៀវភៅ, រូបភាព នឹងក្រដាស់លំហាត់ជាដើម ។

✪ គ្រូនឹងខិតខំជួយលើកទឹកចិត្តសិស្សអោយរៀនឱ្យចេះដឹងច្បាស់លាស់ ដើម្បីរកការងារអ្វីមួយធ្វើនៅថ្ងៃមុខទៀត ។



## សូមទាក់ទងមកយើង...

### អ្នករៀនថ្មី

សូមទូរស័ព្ទ ឬមកជួបយើងផ្ទាល់នៅការិយាល័យ ឬពឹងឱ្យបងប្អូនមិត្តភក្តិមកសុំជំនួសអ្នកក៏បាន ។ អ្នកចាត់ចែងនឹងរៀបចំពេលឱ្យអ្នកមកធ្វើសម្ភាសដើម្បីអោយដឹងពីសេចក្តីត្រូវការនឹងគោលបំណងរបស់អ្នករៀន នឹងដើម្បីជ្រើសរើសគ្រូ ។

### ស្វាគមន៍គ្រូថ្មី

បើអ្នកចង់មកហាត់រៀនធ្វើគ្រូ ដើម្បីស្ម័គ្រចិត្តទៅបង្រៀនសិស្សដល់ផ្ទះសូមទាក់ទងមកយើង

*គ្រូបង្រៀនត្រូវធ្វើដូចតទៅនេះ:*

✪ ចេះនិយាយនឹងសរសេរអង់គ្លេសស្ទាត់ ។

✪ អាចចំណាយពេល ២ឬ៣ម៉ោងបានក្នុងមួយអាទិត្យ ។

✪ ចេះរាក់ទាក់គួរសមចំពោះអ្នកសាសន៍ដ៏ទៃដែលមកពីប្រទេសផ្សេងៗតាមរបៀបខុសៗគ្នា ។

បើចង់បានពតិមានថែមទៀត :

**ESOL: English for Speakers of Other Languages**

: អង់គ្លេសសំរាប់អ្នកនិយាយភាសាដទៃទៀត

# ចាប់ផ្តើមជីវិតថ្មីនៅទីនេះ ជាការពិបាកបន្តិច

Khmer



# ជាពិសេសបើអ្នកមិនចេះ និយាយភាសាអង់គ្លេស

National Association of
ESOL Home Tutor Schemes Inc.
www.esolht.org.nz

# នេះជាកន្លែងដែលគេអាចជួយអ្នកបាន

## ក្រុមគ្រូបង្រៀនភាសាអង់គ្លេស ESOL ដល់ផ្ទះ

យើងជាក្រុមសមាគមសំរាប់ជួយជនភៀសខ្លួននឹងជនពីស្រុកក្រៅចូលមកនៅញូស៊ីឡែនឱ្យរៀនភាសាអង់គ្លេស ដើម្បីចាប់ផ្តើមជីវិតថ្មីនៅប្រទេសញូស៊ីឡែន។

## អ្នកណាដែលអាចរៀនអង់គ្លេសជាមួយយើង ?

គ្រប់មនុស្សពេញវ័យទាំងអស់ដែលនិយាយភាសាផ្សេងគ្នាមករស់នៅក្នុងប្រទេសញូស៊ីឡែនហើយត្រូវការជំនួយខាងភាសាអង់គ្លេស ដើម្បីសំរួលការរស់នៅក្នុងសមាគមប្រទេសថ្មី ។

អ្នកទាំងអស់នោះ ខ្លះបានរៀនភាសាអង់គ្លេសពីស្រុកគេខ្លះមកហើយ តែគេចង់ឱ្យចេះបានច្រើនថែមទៀតដើម្បីរកការងារធ្វើនឹងមានមិត្តភក្តិ ។ អ្នកខ្លះទៀតនិយាយគ្នាជាភាសាអង់គ្លេសជាការពិសោធន៍ថ្មីហើយពិបាកណាស់ ។

គ្រូបង្រៀនទាំងប៉ុន្មានក្នុងក្រុមយើងអាចជួយសំរួលការពិសោធន៍ថ្មីនេះ ។

គ្រូទាំងអស់នឹងខំជួយឱ្យអ្នករៀនភាសាឆាប់ចេះ ហើយរាប់អានដូចជាមិត្តភក្តិជាមួយអ្នក ។





គាំទ្រជួយឱ្យឆាប់ចេះភាសាអង់គ្លេសក្នុងការកសាងជីវិតថ្មី ។

## អ្នកណាជាគ្រូបង្រៀនដល់ផ្ទះ ?

ប្រជាជនធម្មតាដែលស្ម័គ្រចិត្តមកចុះឈ្មោះរៀន ដើម្បីធ្វើជាគ្រូបង្រៀនដល់ផ្ទះជាមួយក្រុមបង្រៀនភាសាអង់គ្លេស ESOL ។ គ្រូ ESOL បង្រៀនដល់ផ្ទះ ជួយអ្នកឱ្យឆាប់ចេះអង់គ្លេស ដើម្បីចូលរួមជាមួយប្រជាជនថ្មី ។

អ្នកស្ម័គ្រចិត្តទាំងប៉ុន្មានត្រូវទៅរៀនរបៀបបង្រៀនសិន ដើម្បីឱ្យចេះបង្រៀនត្រឹមត្រូវល្អ ។ របៀបបង្រៀននេះមានបញ្ចូលទាំងការយោគយល់អំពីទំនៀមទំលាប់ ប្រពៃណីយ ផ្សេងៗគ្នានឹងអំពីរបៀបរៀនសូត្រខុសៗគ្នានៃប្រទេសនីមួយៗ នឹងភាសាអង់គ្លេសដែលត្រូវការចាំបាច់សំរាប់ប្រើប្រាស់រាល់ថ្ងៃ ។

ក្នុងមួយអាទិត្យ គ្រូយើងបង្ហាត់សិស្សបានលើសពី ២៥០០ នាក់ ។ គ្រូទៅបង្រៀនដល់ផ្ទះសិស្សតែម្តងរាល់អាទិត្យ ។

## លទ្ធផលល្អរបស់ក្រុមគ្រូបង្រៀនដល់ផ្ទះ

គ្រូអាចជួយបង្រៀនអ្វីដែលសាលាអង់គ្លេសផ្សេងទៀតមិនអាចធ្វើបាននឹងអោយសមរម្យទៅតាមសេចក្តីត្រូវការរបស់សិស្ស ។

យើងធានាថា នឹងជួយបង្រៀនឱ្យបានស្រួលចំពោះសិស្សណាដែលមិនសូវបានរៀនសូត្រត្រឹមត្រូវពីដើមមក ។

ម៉ោងពេលរៀនអាចផ្លាស់ប្តូរបានទៅតាមពេលទំនេររបស់សិស្ស នឹងគ្រូក្រៅម៉ោងធ្វើការនឹងកិច្ចការផ្ទះ ។

រៀនយូរទៅគ្រូនឹងសិស្សរាប់អានគ្នាទៅវិញទៅមក ហើយប្តូរគ្នារៀនអំពីទំនៀមទំលាប់ប្រពៃណីពីស្រុករៀងៗខ្លួន ។

យេងមានរៀបចសកម្មភាពផ្សេងៗថែមទៀត ដេម្បីឲ្យការសិក្សានឹងជីវិតកាន់តែសប្បាយលូតលាស់ល្អនៅក្នុងប្រទេសញូស៊ីឡែន ។

- ✪ ជួបជុំគ្នាលេងជាក្រុមដើម្បីហាត់និយាយអង់គ្លេស
- ✪ ថ្នាក់រៀនភាសាអង់គ្លេស ESOL
- ✪ ក្រុមបង្ហាត់ចំណេះពិសេសៗ
- ✪ នាំដើរលេងទៅកន្លែងផ្សេងៗ
- ✪ ប្រជុំគ្នារៀបពិធីផ្សេងៗតាមទំលាប់ប្រទេសខុសៗគ្នា
- ✪ លំហាត់ក្រៅសាលាមានកីឡា ឬកម្មវិធីផ្សេងៗ
- ✪ ព្រឹត្តប័ត្រ
- ✪ កម្មវិធីភាសាអង់គ្លេសសំរាប់ប្រជាជនស្រុកក្រៅដែលបង់ប្រាក់ថ្លៃរៀនភាសាឱ្យមកក្រសួងអន្តោប្រវេសន៏ជាមុនដើម្បីចូលរៀនសាលាអង់គ្លេសពេលគេមកដល់ប្រទេសញូស៊ីឡែននោះក៏មានដែរ តែមិនច្រើនកន្លែងទេ ។

National Association of
ESOL Home Tutor Schemes Inc.